ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...១០៧១... សហវ.-ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ពន្ធនិងអាករជាបន្ទុករដ្ឋ លើការនាំចូលរថយន្តឯកជន របស់មន្ត្រីការទូតជាន់ខ្ពស់ មកពីក្រៅប្រទេស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងចំណារដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ លើលិខិតលេខ ៩១៨៤ សហវ.អគរ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

**សម្រេច**

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការលើកទឹកចិត្តពន្ធនិងអាករ លើការនាំចូលរថយន្តឯកជនរបស់មន្ត្រីការទូតជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ដែលបានត្រឡប់មកពីបំពេញបេសកកម្មក្រៅប្រទេស និងកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរដល់ចំណូលពន្ធអាករគយលើផ្នែកយានយន្ត។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅ÷

- កំណត់នូវឋានៈមន្ត្រីការទូតជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ដែលអាចស្នើសុំការលើកទឹកចិត្តពន្ធនិងអាករលើការនាំចូលរថយន្តឯកជន
- កំណត់នូវនីតិវិធី និងលក្ខខណ្ឌនៃការនាំចូលរថយន្តឯកជនរបស់មន្ត្រីការទូតជាន់ខ្ពស់ ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ និងកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការនាំចូលរថយន្តឯកជនរបស់មន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានត្រឡប់មកពីបំពេញបេសកកម្មក្រៅប្រទេស។

**ប្រការ ៤.-**

ត្រូវបានដាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ លើការនាំចូលរថយន្តឯកជនរបស់មន្ត្រីការទូតជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ដែលបានត្រឡប់មកពីបំពេញបេសកកម្មក្រៅប្រទេស និងបានបំពេញតាមលក្ខខណ្ឌនានាដូចខាងក្រោម÷

ក. អ្នកស្នើសុំជាមន្ត្រីការទូតជាន់ខ្ពស់របស់រដ្ឋ ដែលមានមុខតំណែងជាឯកអគ្គរាជទូត អគ្គរាជទូត សម្រាប់ឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស ដែលទើបត្រឡប់ពីបំពេញភារកិច្ចផ្លូវការរយៈពេលលើសពី ០១ឆ្នាំ នៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។

ខ. រថយន្តជាប្រភេទប្រើរួច និងជាកម្មសិទ្ធិផ្ទាល់ខ្លួនដែលមានលិខិតគតិយុត្តិបញ្ជាក់ថាជាកម្មសិទ្ធិយ៉ាងតិច ០៦ខែ គិតត្រឹមថ្ងៃវិលត្រឡប់ចូលប្រទេសវិញ និងមិនលើសពី ០១គ្រឿង សម្រាប់ឧត្តមមន្ត្រីការបរទេសម្នាក់។

គ.រថយន្តដែលទទួលបានការអនុគ្រោះតាមបញ្ញត្តិប្រកាសនេះ ត្រូវកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ក្នុងករណីម្ចាស់រថយន្តចង់លក់-ផ្ទេរទៅតតិយជន សាមីជនត្រូវ

បំពេញកាតព្វកិច្ចពន្ធដែលនៅសេសសល់ជាមុន និងទទួលបានការអនុញ្ញាតឱ្យលុបចេញពីបញ្ជីសារពើភណ្ឌជាទ្រព្យសម្បត្តិរបស់រដ្ឋវិញ។

ឃ. ត្រូវមានការសម្រេចជាមុនតាមករណីនីមួយៗពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៥.-**

ការកំណត់លក្ខខណ្ឌនានាដូចមានបញ្ញត្តិក្នុងប្រការ៤ នៃប្រកាសនេះ មិនមានវិសាលភាពលើការអនុញ្ញាតឱ្យនាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ តាមករណីជាក់ស្តែងនីមួយៗតាមការសម្រេចរបស់ស្ថាប័នរាជរដ្ឋាភិបាលមានសមត្ថកិច្ចនានា សម្រាប់ការនាំចូលរបស់អង្គទូត អង្គការអន្តរជាតិ ស្ថាប័នរដ្ឋ ឬឯកសិទ្ធិបុគ្គលផ្សេងទៀត តាមច្បាប់និងបទប្បញ្ញត្តិជាធរមាននោះទេ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលនិងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវចាត់ចែង និងអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០១៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ